# វង់តន្ត្រីគ្រឹម

អត្ថបទនេះ ពាក់ព័ន្ធនឹងវង់តន្ត្រីគ្រឹម ភូមិត្បែង ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលខ្ញុំបានស្រាវជ្រាវ និងសង្កេតផ្ទាល់នាពេលថ្មីៗនេះ រួមជាមួយនឹងលោកគ្រូ សាស្ត្រាចារ្យតន្ត្រីមួយចំនួនមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

«គ្រឹម» ជាឈ្មោះដែលគេហៅទៅតាម «ដើងស្គរ» ដែលឮសូរ «គ្រឹមៗ»។ វង់តន្ត្រីគ្រឹមភូមិត្បែង លេងកំដរពិធីអាពាហ៍ពិពាហ៍នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣ នៅភូមិរវៀងតាទុំ ឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ប្រើឧបករណ៍តន្ត្រី៖ ស្គរគ្រឹម៣, ប៉ីប្រុស (ប៉ីអ) ១, ទ្រសោតូច១,[១] ទ្រអ៊ូ១, ក្រពើ (តាខេ)១, ឃឹមតូច១, ឈឹង១គូ, និងអ្នកច្រៀង៤នាក់។ ចំពោះតម្លៃនៃការសម្តែងក្នុងមួយថ្ងៃឬមួយពិធី គឺគេយក ២០០ដុល្លារសហរដ្ឋអាមេរិក។

ទោះបីមានឈ្មោះដូចគ្នាក៏ដោយ ក៏ការបកស្រាយបទនិងចម្រៀង ជាពិសេសដើងស្គរគឺមានភាពខុសប្លែកពីគ្នារវាងតន្ត្រីអាពាហ៍ពិពាហ៍ខ្មែរកណ្តាលនិងតន្ត្រីគ្រឹម។ ចំពោះការរឹតសំឡេងឧបករណ៍តន្ត្រីនៅក្នុងវង់តន្ត្រីគ្រឹម យោងតាមសម្ភាសន៍ជាមួយនឹងតន្ត្រីករគ្រឹម គាត់បានប្រាប់យើងថា គេរឹតសូរ «៥ជាន» ឬទៅតាម «ក» (គឺបំពង់កេរបស់អ្នកច្រៀង)។ លោក ឈឿន វាស្នា បានសរសេរថា «លក្ខណៈពិសេសនៃវង់តន្ត្រីនេះ គឺទំនុកច្រៀងនិងចង្វាក់ស្គរ»។[២] ហើយអ្នកច្រៀង ច្រៀងដោយឥតព្រៀងទុក គឺច្រៀងទៅតាមកម្មវិធីនៃមង្គលការ។

នាអតីតកាល គ្រូធំរបស់តន្ត្រីគ្រឹម គឺលោកគ្រូ ហង្ស បូរ បច្ចុប្បន្នមានកូនប្រុសឈ្មោះ បូរ សម្រស់ ជាអ្នកបន្តវេន។ លោក បូរ សម្រស់ ចេះលេងឧបករណ៍ប៉ីប្រុស (ប៉ីអ) ទ្រ និងច្រៀងផង។ វង់តន្ត្រីគ្រឹមភូមិត្បែង ដឹកនាំដោយលោកគ្រូ សើម ព្រេម ជាប្រធានក្រុមនិងជាអ្នកកូតទ្រសោតូច ដែលមានកូនស្រីរបស់គាត់ឈ្មោះ ស្រី ឡែន ជាអ្នកច្រៀង និងម្នាក់ទៀតជាអ្នកវាយស្គរគ្រឹម។ លក្ខណៈពិសេសមួយទៀតរបស់វង់តន្ត្រីគ្រឹមនេះ គឺស្គរគ្រឹម

[១] ខ្ញុំសូមធ្វើការកត់សម្គាល់ផងដែរថានៅក្នុងវង់តន្ត្រីគ្រឹម ស្រុកព្រះដាក់ (និយមហៅថា «ប្រដាក») គេប្រើទ្រខ្មែរ (ទ្រខ្សែ៣) ជំនួសទ្រសោតូច ដូចនៅក្នុងទម្រង់វង់តន្ត្រីអាពាហ៍ពិពាហ៍ខ្មែរកណ្តាល ដែលខុសគ្នាពីតន្ត្រីអាពាហ៍ពិពាហ៍ខ្មែរបុរាណដូច្នោះដែរ (ឈឿន វាស្នា (ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣))។

[២] ពិធីមង្គលការរបស់ប្រជាជនស្រុកបន្ទាយស្រី ខេត្តសៀមរាប: ២០២៣.ទំព័រ២

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

វាយដោយអ្នកច្រៀងខ្លួនឯងតែម្ដង។ ស្គរគ្រឹម មានបី៖ ស្គរឪ ឬស្គរឈ្មោល (ទំហំនិងសូរ ធំជាងគេ) ស្គរម៉ែ ឬស្គរញី (ទំហំនិងសូរ ធំកណ្ដាល) និងស្គរកូន (ទំហំនិងសូរ តូចជាងគេ)។

មុននឹងសម្ដែង គេរៀបរណ្ដាប់ថ្វាយគ្រូមាន៖ អង្ករជ័យ ស្លាធម៌ បាយសី បារី ម្លូ ស្លា (ស្លាកន្សែង ស្លាដក់ ស្លាព័ន្ធ) ទៀន ធូប ម្ហូបអាហារ ចេកទុំ នំ (នំគម អន្សម) ចំណី បង្អែម និងផ្លែឈើ។ ម្ហូបមាន មាន់២ (ហៅថា «ដំបងក្អែម») បាយប្រអប់ (ខ្លះហៅថា តាប៉ែ)។

ពិធីអាពាហ៍ពិពាហ៍ រួមមានពិធីសំពះព្រះអាទិត្យយកពេលា ធ្វើឡើងនៅវេលាម៉ោង៥ភ្លឺ ដឹកនាំដោយអាចារ្យ សូត្រធម៌ បួងសួងសុំសេចក្ដីសុខ សិរីសួស្ដី ជ័យមង្គលចូលមានដល់គូស្វាមីភរិយាថ្មី ក្រុមគ្រួសារ ញាតិសន្ដាន និងភ្ញៀវកិត្តិយសចូលរួមនៅក្នុងពិធីអាពាហ៍ពិពាហ៍។ នៅវេលាម៉ោង៧ព្រឹក គេធ្វើពិធីហែកូនកំលោះទៅចូលរោងជ័យ ដើម្បីសុំផ្លូវដើរជណ្ដើរឡើង។ នៅក្នុងពិធីនេះ គេមិនលេងបទ «ចៅព្រាហ្មណ៍» ទេ គឺគេលេងបទឡកវន្ទើនរបៀបដើងស្គរឆៃយ៉ាំសម្ដែងក្នុងពេលហែកបិនទៅវិញ។ នៅក្នុងពិធីសែនចងដៃសង្កត់ព្រលឹង គេលេងបទ «បាយខុន» ដោយមានវាយឃ្មោះផង។ ពេលអ្នកច្រៀងពីរនាក់ប្រុសស្រីតំណាងឱ្យទេវតានិងទេពអប្សរ ច្រៀងរៀបរាប់នៅក្នុងពិធីរាប់ផ្លែឈើទាំង៣៦មុខចប់សព្វគ្រប់អស់ហើយ នៅពេលដល់កំណត់ត្រូវវិលត្រឡប់ទៅវិញតាមសំពៅមាសសំពៅប្រាក់ វង់តន្ត្រីគ្រឹមលេងបទ «សំពៅថយ»។

សរុបសេចក្ដីមក គឺនៅក្នុងពិធីអាពាហ៍ពិពាហ៍ទាំងមូល គេប្រើវង់តន្ត្រីគ្រឹមទាំងស្រុងតាំងពីដើមដល់ចប់ ដើម្បីលេងភ្លេងនិងច្រៀងចម្រៀងអាពាហ៍ពិពាហ៍។ គ្រូភ្លេងចាស់ៗ និងអាចារ្យកាន់កម្មវិធីមង្គលការ បានមានប្រសាសន៍ថា ខ្មែរយើងមិនសូវនិយមប្រើប្រាស់វង់តន្ត្រីគ្រឹមទេនៅក្នុងពិធីអាពាហ៍ពិពាហ៍នាពេលបច្ចុប្បន្ននេះ។ ប្រពៃណីនិងការប្រើប្រាស់វង់តន្ត្រីគ្រឹមនេះ គឺមាននៅសេសសល់តែ ជាពិសេស ក្នុងខេត្តសៀមរាបតែប៉ុណ្ណោះ៕

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

# ឯកសារពិគ្រោះ

ឈឿន វាសនា. (២០២៣). *ពិធីមង្គលការរបស់ប្រជាជនស្រុកបន្ទាយស្រី ខេត្តសៀមរាប*. ភ្នំពេញ: រាជបណ្ឌិត្យសភាកម្ពុជា។

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង